Massachusetts League
of Community Health Centers

# វ៉ាក់សាំង COVID-19៖ សំណួរទូទៅ និងកង្វល់

## តើវ៉ាក់សាំង COVID-19 ប្រភេទអ្វី និងតើវាមានប្រសិទ្ធិភាព យ៉ាងណា?

នៅឥឡូវនេះ មានវ៉ាក់សាំងបីមុខ មកពីក្រុមហ៊ុន Pfizer, Moderna, និង Johnson & Johnson។ មួយមុខដែលមានសំរាប់អ្នក អាស្រ័យលើការផ្គត់ផ្គង់ទូទៅ និងកន្លែងចាក់វ៉ាក់សាំង។ វ៉ាក់សាំង Pfizer និង Moderna មានប្រសិទ្ធិភាពដូចគ្នា។ វាមានវីរុសបន្តិចបន្តួច ប៉ុន្តែមិនមែនទាំងស្រុងទេ។ ការទទួលវ៉ាក់សាំង បង្ហាត់ខ្លួនរបស់អ្នក ឲ្យស្គាល់វីរុស និងសំឡាប់វា។ វ៉ាក់សាំង Pfizer និង Moderna ទាំងពីរមុខ ត្រូវការពីរដូស្ស។

រីឯវ៉ាក់សាំង Johnson & Johnson គឺខុសពីគេ។ វាប្រើវីរុសផ្តាសាយទូទៅដែលងាប់ ដើម្បីយកមួយដុំតូចនៃវីរុស COVID-19 ចូលទៅក្នុងខ្លួនរបស់អ្នក។ វាត្រូវការតែមួយដូស្សប៉ុណ្ណោះ។ វ៉ាក់សាំង Johnson & Johnson មិនការពារបានល្អ ប្រឆាំងនឹងករណី COVID-19 ធុនស្រាលទេ ប៉ុន្តែវាការពារបានល្អ ប្រឆាំងនឹងជំងឺធ្ងន់ធ្ងរ។

## តើឥទ្ធិពលរាយរងនៃវ៉ាក់សាំង COVID-19 មានអ្វីខ្លះ?

វាអាចនឹងឈឺនៅនឹងកន្លែង ដែលអ្នកបានចាក់ឆ្នាំ។ អ្នកក៏អាចនឹងអស់កំឡាំង មានគ្រុន និងមានឈឺក្បាល ឬខ្លួន។ ឥទ្ធិពលរាយរងទាំងនេះ គឺល្អទេតើ! វាមានន័យថា ខ្លួនរបស់អ្នកកំពុងតែស៊ាំ រោគ។ ដ៏កម្រមានណាស់ ដែលមនុស្សមានប្រតិកម្ម ចំពោះវ៉ាក់សាំង ភ្លាមៗបន្ទាប់ពីទទួលវា។ ដោយហេតុនោះបានជាអ្នកជំងឺត្រូវតែរង់ចាំ 15-30 នាទី បន្ទាប់ពីទទួលវ៉ាក់សាំងរួច។

## តើវ៉ាក់សាំងបានរួចរាល់យ៉ាងរហ័ស អាចមានសុវត្ថិភាពយ៉ាងណា?

សំរាប់មូលហេតុធំៗបីយ៉ាង។ ទីមួយ ពីព្រោះអ្នកវិទ្យាសាស្ត្រ បានសិក្សាកូរ៉ូណាវីរុស ជាច្រើនឆ្នាំមកហើយ។ ទីពីរ ពីព្រោះតែភាពធ្ងន់ធ្ងរ នៃជំងឺរាតត្បាត អ្នកវិទ្យាសាស្ត្រនៅសព្វទាំងពិភពលោក បានធ្វើការជាមួយគ្នា ដើម្បីរកវ៉ាក់សាំង។ ហើយទីបី សហរដ្ឋអាមេរិក បានបង់ប្រាក់ឲ្យក្រុមហ៊ុនឱសថជាង $12 ពាន់លាន។ ការនេះបានបង់ឲ្យសំរាប់គ្រប់ជំហានទាំងអស់ ដើម្បីផលិតឱសថថ្មី។

### តើវ៉ាក់សាំងមានអ្វីនៅក្នុងវា ដើម្បីតាមដាន ឬត្រួតត្រាមនុស្សឬទេ?

វ៉ាក់សាំងមិននៅក្នុងខ្លួនរបស់អ្នកទេ ដូច្នេះហើយគ្មានអ្វីនៅក្នុងវា ដែលអាចតាមដាន ឬត្រួតត្រាអ្នកឡើយ។ ការទទួលវ៉ាក់សាំង បង្ហាត់ខ្លួនរបស់អ្នក ឲ្យស្គាល់វីរុស និងសំឡាប់វា។ នៅក្នុង ដំណើរការនោះ អ្វីៗចេញពីវ៉ាក់សាំង គឺត្រូវបានបំផ្លាញ។ ដើម្បីរក្សាប្រជាជនឲ្យមានសុខភាពល្អ រដ្ឋម៉ាស្សាជូសេត្ត តាមដានគ្រប់ៗគ្នាដែលទទួលវ៉ាក់សាំង។ តាមច្បាប់ មានតែអ្នកផ្តល់ការថែទាំសុខភាព និងមន្ត្រីសុខភាពប៉ុណ្ណោះ ដែលអាចឃើញការនេះ។

### ខ្ញុំមិនទុកចិត្តរដ្ឋាភិបាល ឲ្យព័ត៌មានសុខភាពមកខ្ញុំឡើយ។

ពិគ្រោះជាមួយអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក អំពីកង្វល់របស់អ្នក និងសួរគេ សំរាប់ប្រភពផ្សេងទៀតដែលទុកចិត្ត។ សង្គមព័ត៌មាន គឺមិនមែនជាកន្លែងល្អ ដើម្បីទទួលព័ត៌មានឡើយ។

### បើសិនខ្ញុំទទួលវ៉ាក់សាំង តើខ្ញុំនឹងជាផ្នែកនៃការពិសោធន៍មួយ ដោយគ្មានការយល់ព្រមពីខ្ញុំឬទេ?

ទេ។ តាមច្បាប់ គ្មាននរណាម្នាក់អាចធ្វើការស្រាវជ្រាវ លើរូបអ្នកបានឡើយ លុះត្រាតែគេប្រាប់អ្នកពីអ្វីៗដែលគេកំពុងធ្វើ ហើយអ្នកក៏ចុះហត្ថលេខាលើទំរង់មួយ ដែលថ្លែងអ្នកយល់ព្រមឲ្យបាននៅក្នុងការពិសោធន៍។

### តើការទទួលវ៉ាក់សាំង COVID-19 អាចប៉ះពាល់លើស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ ក្នុងរបៀបណាមួយឬទេ?

គ្រប់ៗគ្នាគួរតែទទួលវ៉ាក់សាំង រួមទាំងជនអន្តោប្រវេសន៍ ទោះបើស្ថានភាពរបស់គេ ជាយ៉ាងណាក៏ដោយ។ ការទទួលវ៉ាក់សាំង នឹងមិនប៉ះពាល់អ្វីសោះ ជាមួយនឹងអន្តោប្រវេសន៍ឡើយ។ អ្នកនឹងមិនបានចាត់ទុកជាបន្ទុកសាធារណៈ ពីព្រោះតែវាឡើយ។ ច្បាប់ចែងថាអ្នកផ្តល់ការថែទាំសុខភាពត្រូវតែរក្សាព័ត៌មានរបស់អ្នកជំងឺទុកជាសំងាត់។

### ខ្ញុំមិនត្រូវការវ៉ាក់សាំងទេ ពីព្រោះសំរាប់ភាគច្រើន នៃមនុស្សក្មេង/មនុស្សមានសុខភាពល្អ COVID-19 គឺមិនធ្ងន់ធ្ងរទេ។

មនុស្សក្មេង/មនុស្សមានសុខភាពល្អ មួយចំនួនឈឺថ្កាត់ធ្ងន់ធ្ងរណាស់ ជាមួយនឹង COVID-19 ហើយក៏ស្លាប់ដោយសារវាផង។ អ្នកផ្សេងៗ មិនដឹងថាគេមានវាទេ។ មនុស្សទាំងនេះ គឺជាអ្នកដែលចំឡងជំងឺ COVID-19 ជាទីបំផុត។ អ្នកវិទ្យាសាស្ត្រគិតថា ករណីជាច្រើនត្រូវបានរកឃើញ ពីជនណាម្នាក់ដែល

ពុំមានរោគសញ្ញា។ ដូច្នេះហើយ សូម្បីតែបើអ្នកជាមនុស្សក្មេង និង/ឬ មាន សុខភាពល្អក៏ដោយ ការទទួលវ៉ាក់សាំងគឺជាសារៈសំខាន់។ វានឹងរក្សាវីរុស ពីការធ្វើឲ្យមនុស្សផ្សេងៗឈឺថ្កាត់ ជាពិសេស មនុស្សចាស់ៗ និងអ្នកដែលមានលក្ខណៈសុខភាពខ្លះ។

### ខ្ញុំមិនត្រូវការវ៉ាក់សាំងទេ។ សហគមន៍របស់ខ្ញុំ គឺខ្លាំងក្លារួចហើយ ឬខ្ញុំប្រើថ្នាំធម្មជាតិ។

វាជាការអស្ចារ្យ ដែលអ្នកមានសុខភាពល្អហើយនោះ។ ប៉ុន្តែ COVID-19 គឺជាវីរុសថ្មី ដែលខ្លួនរបស់អ្នក មិនទាន់បានជួបពីមុនឡើយ។ ការទទួលវ៉ាក់សាំង នឹងបង្ហាត់ខ្លួនរបស់អ្នក ឲ្យស្គាល់ និងសំឡាប់វីរុស។

### តើវ៉ាក់សាំងនៅក្នុងខ្លួនរបស់ខ្ញុំឬទេ?

ទេ។ ការទទួលវ៉ាក់សាំង បង្ហាត់ខ្លួនរបស់អ្នក ឲ្យស្គាល់វីរុស និងសំឡាប់វា។ នៅក្នុងដំណើរការនោះអ្វីៗចេញពីវ៉ាក់សាំង គឺត្រូវបានបំផ្លាញ។

### តើការស៊ាំរោគ នឹងឋិតថេរយូរប៉ុណ្ណា?

អ្នកវិទ្យាសាស្ត្រមិនទាន់ដឹងនៅឡើយទេ។ វាអាចនឹងជាពីរបីឆ្នាំ។ បើសិនការនេះដូច្នេះមែន មនុស្សអាចនឹងត្រូវការវ៉ាក់សាំងរៀងរាល់ឆ្នាំ ដូចបានធ្វើជាមួយនឹងគ្រុនផ្តាសាយធំដែរ។

### ខ្ញុំបានកើត COVID-19 រួចហើយ។ តើខ្ញុំនៅតែត្រូវការវ៉ាក់សាំងឬទេ?

ត្រូវការ។ អ្នកអាចកើតមាន COVID-19 ជាលើកទីពីរ។ បើសិនអ្នកត្រូវបានព្យាបាល ជាមួយនឹងអង្គបដិបក្ខប្រាណ ឬទឹកផ្លាស្មា អ្នកគួរតែរង់ចាំ 90 ថ្ងៃ មុននឹងទទួលវ៉ាក់សាំង។

### ហានិភ័យរបស់ខ្ញុំមកពីវ៉ាក់សាំង គឺធំធេងជាងហានិភ័យរបស់ខ្ញុំ នៃការឈឺថ្កាត់ខ្លាំង ឬការស្លាប់ដោយសារ COVID។

ការពិត មិនយល់ស្របទេ។ មនុស្សរាប់លាននាក់ នៅក្នុងសហរដ្ឋ បានទទួលវ៉ាក់សាំងរួចហើយ។ មានមួយចំនួនដ៏តូចខ្លាំងណាស់ ដែលមានប្រតិកម្ម។ គ្មានអ្នកណាម្នាក់ បានស្លាប់ដោយសារវាឡើយ។ ដោយប្រៀបធៀបការនោះ ទៅនឹងប្រជាជនអាមេរិកាំងស្ទើរតែកន្លះលាននាក់ ដែលបាន ស្លាប់ដោយសារ COVID-19 រួចហើយ។

### តើវ៉ាក់សាំង បានពិសោធលើមនុស្សដូចខ្ញុំឬទេ ?

វ៉ាក់សាំង Moderna បានពិសោធលើមនុស្ស 30,000 នាក់។ វ៉ាក់សាំង Pfizer បានពិសោធលើមនុស្ស 37,000 នាក់។ ការសិក្សាក៏បានចែកស្មើៗគ្នា រវាងបុរស និងស្ត្រី។ មនុស្សប្រហែល 3000 នៅក្នុងការសិក្សាទាំងពីរ គឺសាសន៍អាស៊ី។ ស្ទើរតែពាក់កណ្តាលនៃមនុស្ស នៅក្នុងការសាកថ្នាំ Pfizer មានលក្ខណៈជំងឺ ដូចជា ធាត់ពេក ជំងឺទឹកនោមផ្អែម ឬជំងឺបេះដូង។

### ខ្ញុំកំពុងតែព្យាយាមឲ្យមានកូន មានគភ៌ ឬបំបៅកូន។ តើខ្ញុំគួរតែទទួលវ៉ាក់សាំង COVID-19 ឬទេ?

ការទទួលវ៉ាក់សាំង មិនបានធ្វើឲ្យស្ត្រីពុំអាចមានគភ៌ទេ។ អ្នកវិទ្យាសាស្ត្រ នៅតែមិនបានដឹងច្រើននៅឡើយ អំពីការមានគភ៌ ឬការបំបៅកូន និងវ៉ាក់សាំងទេ។ ប៉ុន្តែស្ត្រីមានគភ៌ អាចឈឺថ្កាត់ធ្ងន់ធ្ងរណាស់ជាមួយ COVID-19។ បើសិនអ្នកមានគភ៌ ឬបំបៅកូន ត្រូវពិគ្រោះជាមួយ អ្នកផ្តល់ការថែទាំសុខភាព របស់អ្នក អំពីអ្វីៗដែលល្អបំផុត សំរាប់អ្នក និងកូនង៉ែតរបស់អ្នក។

### តើ COVID-19 មានសុវត្ថិភាព សំរាប់មនុស្សដែលមានលក្ខណៈសុខភាពខ្លះ ឬដែលលេបថ្នាំឬទេ ?

វ៉ាក់សាំង គឺមានសុវត្ថិភាព សំរាប់មនុស្សដែលមានលក្ខណៈសុខភាពខ្លះ ឬដែលលេបថ្នាំ។ វាអាចនឹងពុំមានប្រសិទ្ធិភាពល្អទេ បើសិនអ្នកមានបញ្ហាប្រព័ន្ធស៊ាំរោគ ឬសរសៃប្រសាទ។ វាក៏អាចនឹងពុំមានប្រសិទ្ធិភាពល្អដែរ បើសិនអ្នកលេបថ្នាំស្ទើរ៉យ ឬឱសថផ្សេងទៀត សំរាប់ការរលាក។ ពិគ្រោះជាមួយអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក អំពីអ្វីដែលត្រឹមត្រូវសំរាប់អ្នក។

### តើវ៉ាក់សាំងពីរដូស្ស ការពារអ្នកពី COVID-19 រហ័សប៉ុណ្ណា ?

បន្ទាប់ពីដូស្សទាំងពីរមក ខ្លួនរបស់មនុស្សភាគច្រើន អាចសំឡាប់វីរុស COVID-19 បាន។ ប៉ុន្តែអ្នកវិទ្យាសាស្ត្រមិនប្រាកដទេ បើសិនអ្នកនៅតែអាចចំឡង COVID-19 ទៅមនុស្ស ផ្សេងៗ—សូម្បីតែបើអ្នកមិនឈឺថ្កាត់ក៏ដោយ។ ដូច្នេះហើយ អ្នកគួរតែធ្វើតាមវិន័យ អំពីរបៀប ឲ្យបានសុខសប្បាយ អំឡុងពេលនៃជំងឺរាតត្បាត។

## តើវ៉ាក់សាំង COVID-19 មានសុវត្ថិភាព សំរាប់មនុស្សដែលមានលក្ខណៈសុខភាពខ្លះ ឬដែលលេបថ្នាំឬទេ?

វ៉ាក់សាំង គឺមានសុវត្ថិភាព សំរាប់មនុស្សដែលមានលក្ខណៈសុខភាពខ្លះ ឬដែលលេបថ្នាំ។ វាអាចនឹងពុំមានប្រសិទ្ធិភាពល្អទេ បើសិនអ្នកមានបញ្ហាប្រព័ន្ធស៊ាំរោគ ឬសរសៃប្រសាទ។ វាក៏អាចនឹងពុំមានប្រសិទ្ធិភាពល្អដែរ បើសិនអ្នកលេបថ្នាំស្តេរ៉យ ឬឱសថផ្សេងទៀត សំរាប់ការរលាក។ ពិគ្រោះជាមួយអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក អំពីអ្វីៗដែលត្រឹមត្រូវសំរាប់អ្នក។

## តើខ្ញុំអាចកើតជំងឺ COVID-19 សូម្បីតែបន្ទាប់ពីទទួលវ៉ាក់សាំងឬទេ?

បើសិនអ្នកបានឆ្លងរោគ នៅមុនពេលអ្នកបានចាក់វ៉ាក់សាំង អ្នកនៅតែអាចកើតជំងឺ COVID-19—ព្រមទាំងចំឡងវា ទៅមនុស្សផ្សេងៗផង។

## តើក្មេងៗអាចទទួលវ៉ាក់សាំងឬទេ?

មិនទាន់នៅឡើយទេ។ ក្មេងៗនឹងទទួលវ៉ាក់សាំងនៅពេលក្រោយទៀត។ ឥឡូវនេះ ក្រុមហ៊ុនឱសថកំពុងតែសិក្សាទៅលើក្មេងៗ ហើយនឹងបានដឹងនៅរដូវក្តៅ ថាតើគេមានប្រតិកម្មយ៉ាងណា ចំពោះវ៉ាក់សាំង។ មនុស្សក្មេងៗអាយុ 16 ឆ្នាំ ឬចាស់ជាង ដែលមានលក្ខណៈសុខភាពខ្លះ ឬជាអ្នកធ្វើការចាំបាច់ អាចទទួលវ៉ាក់សាំងបានឆាប់ជាង។

## តើវ៉ាក់សាំង ការពារប្រឆាំងនឹងពូជវីរុស COVID-19 ថ្មីឬទេ?

វាឆាប់ពេកដើម្បីដឹងពីការនេះ។ ប៉ុន្តែក្នុងករណីនេះ បើសិន ក្រុមហ៊ុនឱសថកំពុងតែរកមើល របៀបបង្កើតថ្នាំចាក់បន្ថែម សំរាប់មនុស្សដែលបានចាក់វ៉ាក់សាំងរួចហើយ និងការដូរវ៉ាក់សាំង ប្រយោជន៍ដើម្បីឲ្យវាសំឡាប់ពូជវីរុសថ្មីដែរ។

## ចុះបើសិនខ្ញុំបានខាន ជួបតាមការណាត់ជួបរបស់ខ្ញុំ សំរាប់ដូស្សទីពីរនៃវ៉ាក់សាំង?

នោះមិនជាថ្វីទេ។ ធ្វើណាត់ជួបមួយទៀត យ៉ាងឆាប់រហ័សបំផុត ដែលពេញចិត្តគឺក្នុងពេល 6 អាទិត្យនៃដូស្សទីមួយរបស់អ្នក។ ប៉ុន្តែសូម្បីតែបើការនោះមិនកើតឡើងក៏ដោយ អ្នកគួរតែទទួលដូស្សទីពីររបស់អ្នកដដែល។